ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ១៣០/១០- ក្លឹបកូនហ្គោល រ៉ូយ៉ាល់ ខេមបូឌា ភ្នំពេញ**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជកៈ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិតៈ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើៈ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

១- **ភាគីនិយោជក**

ឈ្មោះ : **ក្លឹបកូនហ្គោល រ៉ូយ៉ាល់ ខេមបូឌា ភ្នំពេញ (ស៊ីវីខា អ៊ីនវ៉ែសមិន ឌីវ៉ឺឡឹបមិន ខូ.អែលធីឌី )**

អាសយដ្ឋាន : ភូមិអករដ្ឋល សង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៧៦១ ៧១៧ ទូរសារ : គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ និង ទី២ :

| | |
|---|---|
| ១- លោក ឈិត បូរ៉ាវុធ | មេធាវី |
| ២- លោក ច័ន្ទ អាន | នាយករង |
| ៣- លោក ហាក់ ឡី | រដ្ឋបាល |

២- **ភាគីកម្មករនិយោជិត**

ឈ្មោះ : **- សហព័ន្ធសហជីពឯករាជ្យកម្ពុជា**

**- សហជីពឯករាជ្យកម្មករកម្ពុជាក្រុមហ៊ុន Royal Cambodia Golf Club**

អាសយដ្ឋាន : ភូមិអណ្តូងតាត្រាជ សង្កាត់ក្រសាំង ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៨៨៤ ០៥៧ ទូរសារ : គ្មាន



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី១ និង ទី២ ៖

១- លោកស្រី ទេព គីមវណ្ណារី ប្រធានសហព័ន្ធសហជីពឯករាជ្យកម្ពុជា

២- លោក សំ មុំ ប្រធានសហជីពឯករាជ្យកម្មករកម្ពុជា ប្រចាំក្រុមហ៊ុន

៣- លោក សាយ សុង អនុប្រធានសហជីពឯករាជ្យកម្មករកម្ពុជា ប្រចាំក្រុមហ៊ុន

៤- លោក សុខ ខឿន សមាជិកសហជីព

៥- លោក សៀម សាន សមាជិកសហជីព

៦- លោក ស៊ុន ថៃ សមាជិកសហជីព

៧- កញ្ញា ទូច កូឡាប កម្មករ

៨- កញ្ញា គីម បូរី កម្មករ

៩- កញ្ញា ជិន វណ្ណៈ កម្មករ

១០- កញ្ញា ខាន់ លំអង កម្មករ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនបន្តកិច្ចសន្យាការងារជូនកម្មករទាំងបួនរូប ដើម្បីឱ្យបានចូលធ្វើការវិញ ដោយមូលហេតុអ្នកទាំងបួនជាបុគ្គលិកដែលមានអតីតភាពការងារយូរឆ្នាំ ដូច្នេះការបញ្ចប់កិច្ចសន្យាការងារនេះ គឺភាគីក្រុមហ៊ុនមានការគុំគួន និងរើសអើងចំពោះពួកគាត់។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចទទួលយកកម្មករនិយោជិតទាំងបួនរូបឱ្យចូលធ្វើការវិញបានទេ ព្រោះថា នេះជាការមិនបន្តកិច្ចសន្យាការងារជូន (ដកការកំណត់) ហើយក្រុមហ៊ុនបានទូទាត់នូវប្រាក់បំណាច់ផ្សេងៗ ឱ្យទៅតាមច្បាប់ស្តីពីការងារ។

២- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនបញ្ឈប់លោក ច័ន្ទ អាន ដែលប្រើពាក្យសំដីមិនសមរម្យមកលើកម្មករនិយោជិតកន្លងមក។ ដោយឡែកភាគីនិយោជិតបញ្ជាក់ថា ក្រុមហ៊ុនសុំយកបញ្ហានេះទៅធ្វើការដោះស្រាយផ្ទៃក្នុងសិន ដោយផ្តល់ចម្លើយនៅពេលក្រោយ។

៣- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនបញ្ឈប់លោកប្រធានផ្នែកមេការផ្នែកបាញ់ទឹក (ឈ្មោះ ហុង) ពីការងារ ព្រោះថា គាត់បានប្រព្រឹត្តិកំហុសធ្ងន់ ដូចមានចែងក្នុងមាត្រា៨៣ នៃច្បាប់ស្តីពីការងារ គឺបានវាយតប់ជាមួយបុគ្គលិកម្នាក់ឈ្មោះ សំ សំណាង ហើយត្រូវបានក្រុមហ៊ុនបញ្ឈប់ពីការងារ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនសុំយកបញ្ហានេះទៅធ្វើការដោះស្រាយផ្ទៃក្នុងសិន ដោយផ្តល់ចម្លើយនៅពេលក្រោយ។

THE ARBITRATION COUNCIL

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ (អាណត្តិទី៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ១០៧៣ កប/អក/វក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យតន្ត្រទេវី) សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ :**

- លើកទី១: ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០ (វេលាម៉ោង ១៤:00 នាទី រសៀល)។
- លើកទី២: ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១០ (វេលាម៉ោង ១៤:00 នាទី រសៀល)។

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០ នាយកដ្ឋានវិវាទការងារ បានទទួលបណ្តឹងពីសហព័ន្ធសហជីពឯករាជ្យកម្ពុជា ប្រចាំនៅក្រុមហ៊ុន ស៊ីរីការហ្គោលក្លឹប (Royal Cambodia Golf Club) ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌ ការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះ នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការ ដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើកាផ្សះផ្សាលើកចុងក្រោយ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ ដោយបានទទួលលទ្ធផល មិនសះជាចំនួន ០៣ ចំណុច លើការទាមទារចំនួន ០៧ ចំណុច។ ចំណុចមិនសះជាចំនួន ០៣ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមរយៈរបាយការណ៍ស្តីពីវិវាទការ ងាររួមមិនសះជា លេខ ១០៧៣ ក.ប/អក/វ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០១០។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៣ ចំណុចនេះ

នៅថ្ងៃសវនការលើកទី១ នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ១៤:០០ នាទី រសៀល និងសវនាការលើកទី២ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ១៤:០០ នាទី រសៀល។

ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទាំងពីរលើកនេះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកព័ត៌មានផ្សេងៗដែលទាក់ទងនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចវិវាទមិនសះជាចំនួន ០៣ ចំណុចនេះបន្ថែមទៀត ដែលជាលទ្ធផលភាគីកម្មករនិយោជិត និងនិយោជកបានព្រមព្រៀងគ្នាលើចំនុចវិវាទទី១ និងចំណុចវិវាទទី៣ ភាគីកម្មករនិយោជិតឯកភាពដកចេញពីការទាមទារ ។

ហេតុនេះហើយ ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាតែលើចំណុចវិវាទទី២ តែប៉ុណ្ណោះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុដូចខាងក្រោមៈ

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី**

**អ្នកជំនាញក្រៅពីភាគី : គ្មាន**

**សាក្សី :**

**ក- សាក្សីក្នុងនាមអព្យាក្រឹត្យ: គ្មាន**

**ខ- សាក្សីក្នុងនាមនិយោជកៈ គ្មាន**

**គ- សាក្សីក្នុងនាមកម្មករនិយោជិត**

| | |
|---|---|
| ១- លោក ម៉ម ហ៊ែល | កម្មករ |
| ២- លោក សង សឿន | កម្មករ |
| ៣- លោក ម៉ម ពុំ | កម្មករ |
| ៤- លោកស្រី សាយ សុភាព | អ្នកលក់ |

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- ពាក្យសុំផ្តល់ឯកសារ របស់មេធាវី ឈិត បូរ៉ាវុធ គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការសុំផ្តល់ឯកសារពាក់ព័ន្ធសំណុំរឿងវិវាទការងារលេខ ១៣០/១០ របស់ក្រុមហ៊ុន Royal Cambodia Phnom Penh Golf Club ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១០។

២- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ របស់នាយកក្រុមហ៊ុន Royal Cambodia Phnom Penh Golf Club ប្រគល់សិទ្ធិជូន លោកមេធាវី ឈិត បូរ៉ាវុធ ចុះថ្ងៃទី ខែធ្នូ ឆ្នាំ២០១០។

៣- សារណាសង្ខេប របស់លោកមេធាវី ឈិត បូរ៉ារុធ គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១០។

៤- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម របស់ក្រុមហ៊ុន ស៊ីរីខា អ៊ីនវ៉ែសម៉ិន ឌីវ៉ីឡុបម៉ិន ខូ.អិលធីឌី លេខ ២៣៨៥ ពណ.ចបព ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨។

៥- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន រ៉ូយ៉ាល់ ខេមបូឌា ភ្នំពេញ ហ្គោលក្លឹប ចុះឆ្នាំ២០០១។

៦- ពាក្យបណ្តឹងរបស់ឈ្មោះ សំ សំណាង គោរពជូន លោក ចៅសង្កាត់ត្រពាំងក្រសាំង ស្តីពីប្តឹងឈ្មោះ ហុង មេការរង ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០។

៧- ប័ណ្ណប៉ាតង់ របស់ក្រុមហ៊ុន ស៊ីរីខា អ៊ីនវ៉ែសម៉ិន ឌីវ៉ីឡុបម៉ិន ខូ.អែលធីឌី លេខ DLT.029756.2010 ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១០។

៨- លក្ខន្តិកៈ និង អនុសារណៈ របស់ក្រុមហ៊ុន ស៊ីរីខា អ៊ីនវ៉ែសម៉ិន ឌីវ៉ីឡុបម៉ិន ខូ.អែលធីឌី ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៥។

៩- ប្រវត្តិរូបសង្ខេបនៃបុគ្គលិក-កម្មករ ឈ្មោះ នៅ ប៊ុនឃាង ចុះថ្ងៃ២៦ ខែតុលា ឆ្នាំ២០០៩។

១០- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ នៅ ប៊ុនឃាង។

១១- សំណុំលិខិតពិនិត្យជំងឺ និងវះកាត់ ពីមន្ទីរពេទ្យអង្គឌួង របស់ឈ្មោះ នៅ ប៊ុនហេង ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០។

១២- កិច្ចសន្យាការងាររបស់ឈ្មោះ នង សារ៉ុន ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១០។

១៣- តារាងប្រាក់ខែរបស់ឈ្មោះ នង សារ៉ុន។

១៤- កិច្ចសន្យាការងារបណ្តេតរបស់ឈ្មោះ សំ សំណាង ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១០។

១៥- តារាងប្រាក់ខែរបស់ឈ្មោះ សំ សំណាង។

១៦- កិច្ចសន្យាការងារបណ្តេតរបស់ឈ្មោះ ផាន ពៅ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១០។

១៧- កិច្ចសន្យាការងារបណ្តេតរបស់ឈ្មោះ ផាន ពៅ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១០។

១៨- តារាងប្រាក់ខែរបស់ឈ្មោះ ផាន ពៅ។

១៩- កិច្ចសន្យាការងារបណ្តេតរបស់ឈ្មោះ ខុន មករា ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១០។

២០- តារាងប្រាក់ខែរបស់ឈ្មោះ ខុន មករា។

២១- ប្រវត្តិរូបសង្ខេបនៃបុគ្គលិក-កម្មកររបស់ឈ្មោះ ខុន មករា ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៨។

២២- រាយឈ្មោះសមាជិកក្នុងបន្ទុកគ្រួសារ របស់ឈ្មោះ ខុន មករា។

២៣- លិខិតធានាអះអាងពីអត្តសញ្ញាណ ឬ/និងអាយុ នៃអ្នកសុំចុះឈ្មោះបោះឆ្នោត និងការបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ របស់ឈ្មោះ ខុន មករា ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧។

THE ARBITRATION COUNCIL

២៤- ប្រវត្តិរូបសង្ខេបនៃបុគ្គលិក-កម្មកររបស់ឈ្មោះ ទូច សំណាង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៩។

២៥- សៀវភៅស្នាក់នៅ របស់ឈ្មោះ សំ សំណាង។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- លក្ខន្តិកៈសហជីពឯករាជ្យកម្មករកម្ពុជា ក្រុមហ៊ុន Royal Cambodia Phnom Penh Golf Club ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៩។

២- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីព ឯករាជ្យកម្មករកម្ពុជា ក្រុមហ៊ុន ស៊ីរីការហ្គោលក្លឹប ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៤។

៣- លិខិតលេខ ៥៧៧ កប/អក/វក ចុះថ្ងៃទ១៤ ខែកក្កដា ឆ្នាំ២០០៩ របស់ប្រធាននាយកដ្ឋានវិវាទការងារ ជម្រាបមក លោកប្រធានសហជីពឯករាជ្យកម្មករកម្ពុជា ក្រុមហ៊ុន Royal Cambodia Phnom Penh Golf Club (ស៊ីរីការហ្គោលក្លឹប) ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពអាណត្តិទី២។

៤- កំណត់ហេតុស្តីពីការសាកសួរព័តិមានពីតំណាងកម្មករនិយោជិត នៃក្រុមហ៊ុន ស៊ីរីការហ្គោលក្លឹប ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១០។

៥- ពាក្យបណ្តឹងរបស់ថ្នាក់ដឹកនាំសហជីពឯករាជ្យកម្មករកម្ពុជា ក្រុមហ៊ុន Royal Cambodia Phnom Penh Golf Club គោរពជូន លោកនាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីសំណើមេត្តាជួយដោះស្រាយកម្មករចំនួន ៤ នាក់ ដែលក្រុមហ៊ុនបញ្ឈប់ពីការងារ ចុះថ្ងៃទី០៤ ខែវិច្ឆិកា។

៦- លិខិតលេខ ០៦៤/២០១០ ស.ស.ឯ.ក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០ របស់សហព័ន្ធសហជីពឯករាជ្យកម្ពុជា គោរពជូន លោកប្រធាននាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីសំណើសុំលោកប្រធាននាយកដ្ឋានវិវាទការងារ ជួយធ្វើអន្តរាគមន៍ ពីពាក្យបណ្តឹងរបស់ ខេនឌី និងលក្ខណ្ឌការងារមួយចំនួន។

៧- លិខិតរបស់សហជីពឯករាជ្យកម្មករកម្ពុជា គោរពជូន លោកស្រីប្រធានសហព័ន្ធសហជីពឯករាជ្យកម្ពុជា ស្តីពីសុំលោកស្រីជួយធ្វើអន្តរាគមន៍ពាក្យបណ្តឹងរបស់ ខេនឌី និងលក្ខណ្ឌការងារមួយចំនួន ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០។

៨- លិខិតរបស់សហជីពឯករាជ្យកម្មករកម្ពុជា គោរពជូន លោកអគ្គនាយកក្រុមហ៊ុន ស៊ីរីការហ្គោលក្លឹប ស្តីពីសំណើសុំរកយុត្តិធម៌ឱ្យកម្មការិនីផ្នែក ខេនឌី ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០។ល

៩- ពាក្យបណ្តឹង និងស្នាមមេដៃរបស់ ខេនឌី ដែលបានបំរើការនៅក្នុងក្រុមហ៊ុន ស៊ីវីការហ្គោលក្លឹប គោរពជូន លោកប្រធានសហជីពឯករាជ្យកម្មករកម្ពុជា ស្តីពីសុំប្តឹងលោកនាយកក្រុមហ៊ុន ឈិន ឬ ចានអាន ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១០។

១០- លិខិតគាំទ្រ និងស្នាមមេដៃរបស់កម្មករដែលធ្វើការក្នុងក្រុមហ៊ុន ស៊ីវីការហ្គោលក្លឹប ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០។

១១- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន Royal Cambodia Phnom Penh Golf Club ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន Royal Cambodia Phnom Penh Golf Club លេខ ១០៧៣ ក.ប/អក/វ.ក ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន Royal Cambodia Phnom Penh Golf Club ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លើកទី១ លេខ ៦៩៨ កប/អក/វក/លកអ. ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លើកទី១ លេខ ៦៩៩ កប/អក/វក/លកអ. ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លើកទី២ លេខ ៧១៣ កប/អក/វក/លកអ. ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លើកទី២ លេខ ៧១២ កប/អក/វក/លកអ. ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ក្លឹបកូនហ្គោល រ៉ូយ៉ាល់ ខេមបូឌា ភ្នំពេញ ( ស៊ីវីខា អ៊ីនវ៉ែសមិន ឌីវីឡុបមិន ខូ.អែលធីឌី ) គឺជាក្រុមហ៊ុនបំរើសេវាកម្មវាយកូនហ្គោល។ បច្ចុប្បន្នក្រុមហ៊ុននេះ មានជួលកម្មករនិយោជិត ចំនួន ២៤០ នាក់។
- សហជីពឯករាជ្យកម្មករកម្ពុជា ក្រុមហ៊ុន Royal Cambodia Golf Club គឺជាភាគីដើមបណ្តឹងនៅក្នុងរឿងនេះ។ សហជីពនេះ ទទួលបានការទួលស្គាល់ថ្នាក់ដឹកនាំសហជីព អាណត្តិថ្មី អាណត្តិទី២ នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩។

**ចំណុចវិវាទទី២៖ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបញ្ឈប់លោក ចន្ទ័ អាន ដែលបានប្រើពាក្យសម្តីមិនសមរម្យមកលើកម្មករនិយោជិតកន្លងមក**

- ភាគីកម្មករនិយោជិត និងក្រុមហ៊ុនទទួលស្គាល់ថា ម៉ោងធ្វើការរបស់កម្មករនិយោជិត ពេលព្រឹកចាប់ផ្តើមពីម៉ោង ៧:០០ ដល់ម៉ោង ១១:០០ និងរសៀលចាប់ផ្តើមពីម៉ោង ០១:០០ រហូតដល់ម៉ោង ៥:០០ នាទី។ នៅក្នុងម៉ោងធ្វើការ កម្មករនិយោជិតអាចជួបជុំគ្នា ដើម្បីបរិភោគអាហារនៅក្នុងបរិវេណរបស់ក្រុមហ៊ុន។
- ភាគីសហជីពបញ្ជាក់ថា នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១០ ប្រហែលម៉ោង ៤ រសៀល នៅកន្លែងលក់បាយ នៅក្នុងបរិវេណរបស់ក្រុមហ៊ុន លោក ស៊ុន ថៃ បានសួរទៅលោក ចន្ទ័ អាន ថា *"បើក្រុមហ៊ុនកាប់ផ្លូវបែបនេះ តើកម្មការិនីផ្នែក ខែនឌី បានផ្លូវអ្វីឆ្លងកាត់?"* ពេលនោះលោក ចន្ទ័ អាន បានឆ្លើយតបដោយប្រើពាក្យសម្តីមើលងាយមកលើកម្មការិនីផ្នែកខេនឌី ថា *"នេះជាសិទ្ធិរបស់ខ្ញុំ ដូចជាកម្មការិនីទាំងអស់នៅផ្នែក ខេនឌី ខ្ញុំចង់នាំទៅក្រៅពេលណាក៏បាន "*។ ភាគីសហជីពបានអះអាងថា កម្មករនិយោជិតដែលបានឮលោក ចន្ទ័ អាន ប្រើពាក្យសម្តីមើលងាយនោះ មានដូចជា (១) លោក សំ មុំ ជាប្រធានសហជីព (២) លោក សុខ ឃឿន ជាលេខាសហជីព (៣) លោក សៀម សាន ជាសមាជិក (៤) លោក ស៊ុន ថៃ ជាសមាជិក (៥) លោក ម៉ម ហៃល ជាកម្មករ (៦) លោក ម៉ម ពុំ ជាកម្មករ (៧) អ្នកលក់ឈ្មោះ សាយ សុភាព។
- ភាគីសហជីពបានផ្តល់ស្នាមមេដៃ និងឈ្មោះកម្មការិនីផ្នែក ខេនឌី ចំនួន ៨៩ នាក់ បានដាក់ពាក្យប្តឹងមកសហជីព នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១០ ទាមទារឱ្យក្រុមហ៊ុនបញ្ឈប់លោក ចន្ទ័ អាន ដោយសារគាត់ប្រើពាក្យសម្តីមើលងាយមកលើកម្មការិនីផ្នែក ខេនឌី។

- នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០ សហជីពបានដាក់ពាក្យបណ្ដឹងរបស់កម្មការិនីផ្នែក ខែនឌី ចំនួន ៨៩ នេះ ជូនទៅក្រុមហ៊ុន ។
- ភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនដែលទទួលបានពាក្យបណ្ដឹងពីកម្មករនិយោជិតណាមួយដែលចោទថា លោក ចន្ទ័ អាន បានប្រើពាក្យសម្ដីមិនសមរម្យនោះទេ។ ប៉ុន្តែ ក្រោយពេលដែលក្រុមហ៊ុនទទួលបានពាក្យបណ្ដឹងរបស់សហជីពឯករាជ្យកម្មករកម្ពុជា នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១០ ក្រុមហ៊ុនបានហៅលោក ចន្ទ័ អាន មកសួរ។ លោក ចន្ទ័ អាន បានឆ្លើយថា គាត់មិនដែលប្រើពាក្យមើលងាយមកលើកម្មការិនីផ្នែក ខែនឌី ដូចការចោទប្រកាន់របស់សហជីពនោះទេ។ ប៉ុន្តែ គាត់ធ្លាប់បានប្រើពាក្យ (មីនេះ មីនោះ) មកលើកម្មការិនីផ្នែក ខែនឌី តែប៉ុណ្ណោះ។ ហេតុនេះ ក្រុមហ៊ុនក៏បានធ្វើការព្រមានដល់លោក ចន្ទ័ អាន ឱ្យឈប់ប្រើពាក្យមិនសមរម្យ (មីនេះ មីនោះ) មកលើកម្មការិនីផ្នែក ខែនឌី ទៀត។ ភាគីនិយោជកអះអាងថា ក្រុមហ៊ុននឹងដាក់ទណ្ឌកម្មទៅលើបុគ្គលិក ឬកម្មករនិយោជិតណាម្នាក់ដែលបានធ្វើខុសទៅនឹងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ។
- ដើម្បីបញ្ជាក់ឱ្យបានច្បាស់ថា មានការប្រើពាក្យសម្ដីមើលងាយមកលើកម្មការិនីផ្នែក ខែនឌី ដែរ ឬអត់នោះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានកំណត់ថ្ងៃសវនាការលើកទី២ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ វេលាម៉ោង ២ ដើម្បីឱ្យភាគីទាំងពីរនាំសាក្សីដែលបាននៅកន្លែងកើតហេតុមកបញ្ជាក់។
- នៅថ្ងៃសវនាការលើកទី២ ភាគីសហជីពបាននាំសាក្សីចំនួន ៤ នាក់ មានដូចជា (១) កម្មករឈ្មោះ ម៉ម ហ៊ែល (២) កម្មករឈ្មោះ សង សារឿន (៣) កម្មករឈ្មោះ ម៉ម ពុំ (៤) អ្នកលក់ ឈ្មោះ សាយ សុភាព។ ភាគីនិយោជកមិនបាននាំសាក្សីមកបំភ្លឺទេ ប៉ុន្តែ លោក ចន្ទ័ អាន និងលោក ហាក់ ឡី ជារដ្ឋបាលមានវត្តមាននៅក្នុងសវនាការលើកទី២ នេះ។
- ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានហៅសាក្សីចំនួន ៤ នាក់ ចូលមកបន្ទប់សវនាការ ដើម្បីមកផ្ដល់កាស្សិណសាក្សីនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្ដាល និងភាគីទាំងពីរ។ មុននឹងផ្ដល់កាស្សិណសាក្សី សាក្សីទាំង៤ នាក់នេះ បានធ្វើការស្បថ និងចុះហត្ថលេខានៅលើលិខិតសច្ចាប្រណិធាននោះ។ សាក្សីទាំង៤ នាក់នេះ បានបញ្ជាក់ថា ខ្លួនបានឮលោក ចន្ទ័ អាន ប្រើពាក្យមើលងាយមកលើកម្មការិនីផ្នែក ខែនឌី មែន។ សាក្សីទាំង៤ នាក់នេះ និយាយថា ពួកគាត់ស្ថិតនៅចម្ងាយប្រហែល ៣ ទៅ ៤ ម៉ែត្រ ពីលោក ចន្ទ័ អាន។

- លោក ចន្ទ័ អាន បញ្ជាក់ថា លោកមិនបានប្រើពាក្យមើលងាយទេ។ លោកបន្តថា លោក សំ មុំ ធ្លាប់មានការអាក់អន់ចិត្តខ្លះៗជាមួយគាត់ ដូចជា (១) ការដេញថ្លៃទិញឡានរបស់ក្រុមហ៊ុន (២) ករណីសន្តិសុខ (៣) ករណីឈ្មោះ ពេជ្រ។ លោក ចន្ទ័ អាន មិនបានធ្វើការបកស្រាយជាក់លាក់ទៅលើករណីទាំង៣នេះ។ លោកបញ្ជាក់ថា នៅថ្ងៃកើតហេតុ លោកបានប្រាប់លោក សំ មុំ ថា ឈប់ឱ្យការមានយល់ច្រលំមកលើគាត់ទៀត។
- ភាគីនិយោជកនៅតែប្រកាន់ជំហរថា ក្រុមហ៊ុនមិនអាចបញ្ឈប់លោក ចន្ទ័ អាន ពីការងារបានទេ។

**ហេតុផលនៃសេចក្តីសម្រេចៈ**

**ចំណុចវិវាទទី២ៈ កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបញ្ឈប់លោក ចន្ទ័ អាន ដែលបានប្រើពាក្យសម្តីមិនសមរម្យមកលើកម្មករនិយោជិតកន្លងមក**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាថា តើកម្មករនិយោជិតមានសិទ្ធិទាមទារឱ្យក្រុមហ៊ុនបញ្ឈប់លោក ច័ន្ទ អាន ពីការងារដែរ ឬទេ នៅពេលដែលគាត់បានប្រើពាក្យមិនសមរម្យមកលើកម្មការិនីផ្នែក ខែនឌ៊ី?

មាត្រា៦៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការងារចែងថា " *កិច្ចសន្យាការងារ គឺជាកិច្ចសន្យាដែលបង្កើតឱ្យមានការទាក់ទងផ្នែកការងារ រវាងកម្មករនិយោជិត និងនិយោជក។ កិច្ចសន្យានេះត្រូវនៅក្រោមវិធានអាជ្ញាគតិ ហើយអាចនឹងធ្វើទៅតាមទំរង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា។...*"

មាត្រា១ នៃក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ចែងថា "*កិច្ចសន្យា គឺជាឆន្ទៈព្រមព្រៀងរវាងបុគ្គលពីរនាក់ ឬច្រើននាក់ ដើម្បីបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ចមួយ ឬច្រើនដែលទាក់ទិននឹងខ្លួន។...*"

យោងតាមមាត្រា៦៥ នៃច្បាប់ស្តីពីការងារ និងមាត្រា១ នៃក្រឹត្យច្បាប់លេខ៣៨ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដែលមានសិទ្ធិក្នុងការបញ្ចប់កិច្ចសន្យា គឺមានតែភាគីនៃកិច្ចសន្យាតែប៉ុណ្ណោះពោលគឺ ភាគីនិយោជក និងកម្មករនិយោជិតនីមួយៗនៃកិច្ចសន្យាការងារ។ ភាគីទីបីមិនមានសិទ្ធិក្នុងការរំលាយកិច្ចសន្យាការងាររវាងនិយោជក និងកម្មករនិយោជិតម្នាក់ៗទេ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១០៨/០៨-ហ៊ូ ហ្គោ ហេតុផលចំណុចវិវាទទី៤)*។

ទន្ទឹមនឹងនេះដែរ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "*កម្មករនិយោជិត មិនមានសិទ្ធិបញ្ជា ឬទាមទារឱ្យភាគីនិយោជកបញ្ឈប់ រឺផ្លាស់ប្តូរកម្មករនិយោជិតណាម្នាក់ពីការងារឡើយ លើកលែងតែកម្មករនិយោជិត អាចផ្តល់ភស្តុតាងបញ្ជាក់ឱ្យឃើញថា កម្មករនិយោជិតនោះជាមនុស្សគ្រោះថ្នាក់ ដែលមិនអាច*

ARBITRATION COUNCIL

*រក្សាទុកក្នុងក្រុមហ៊ុន ឬរោងចក្របាន ហើយការរក្សាកម្មករនិយោជិតដែលជាមនុស្សគ្រោះថ្នាក់បែបនេះអាចបង្ករ ឬនឹងធ្វើឱ្យមានអសន្តិសុខការងារជាក់លាក់ណាមួយ"។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៤/០៣-ជូស៊ីង ហេតុផលចំណុចវិវាទទី១, លេខ ១៧/០៣-១៨/០៣ ហូ ហ៊ីង ហេតុផលចំណុចវិវាទទី៤, លេខ ៨៧/០៤ ណូបែល ហេតុផលចំណុចវិវាទទី២, លេខ ១១៦/០៧-ប្រេស្តសាន់ ហេតុផលចំណុចវិវាទទី៣ និងលេខ ៥៤/០៨-ចុង យ៉ូវ ហេតុផលចំណុចវិវាទទី៥)។*

នៅក្នុងករណីនេះ ភាគីកម្មករនិយោជិត មិនបានបង្ហាញភស្តុតាងជាក់លាក់ណាដើម្បីបញ្ជាក់ថា លោក ច័ន្ទ អាន ជាមនុស្សគ្រោះថ្នាក់ដែលមិនអាចរក្សាទុកក្នុងក្រុមហ៊ុន ហើយការទុកគាត់ឱ្យបន្តធ្វើការទៀតអាចបង្កឱ្យមានអសន្តិសុខការងារជាក់លាក់ណាមួយដល់សន្តិសុខ ឬសុវត្ថិភាពរបស់កម្មករនិយោជិតនោះទេ។ យោងតាមការឆ្លើយបំភ្លឺរបស់សាក្សី ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា លោក ច័ន្ទ អាន បានប្រើពាក្យមិនសមរម្យ (មើលងាយ) មកលើកម្មការិនីផ្នែក ខែនឌី។ ប៉ុន្តែ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការប្រើការពាក្យសំដីមិនសមរម្យនេះ មិនបានធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ ឬសុវត្ថិភាពរបស់កម្មករនិយោជិតនោះទេ។ ដូចនេះ ការទាមទារឱ្យក្រុមហ៊ុនបញ្ឈប់លោក ច័ន្ទ អាន ពីការងារនេះ ពុំមានមូលដ្ឋានផ្លូវច្បាប់ទេ។

ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងសំណុំរឿងលេខ ២៩/០៨-ថៃរ៉ុង ហេតុផលចំណុចវិវាទទី២ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "*ការប្រើពាក្យសំដីមិនសមរម្យ ឬការជេរប្រមាថ គឺជាទង្វើមិនសមរម្យ ហើយអាចបណ្តាលអោយមានភាពល្អក់កករនៅក្នុងកន្លែងការងារ។ ដូចនេះក្រុមហ៊ុនគួរតែមានវិធានការសមស្របណាមួយដើម្បីបញ្ឈប់នូវទង្វើទាំនោះ និងដើម្បីបង្កបរិយាកាសសន្តិភាពនៅកន្លែងការងារ។*"

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនដែរ។ នៅក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្រុមហ៊ុនបានធ្វើការព្រមានដល់លោក ចន្ទ័ អាន ដែលបានប្រើពាក្យមិនសម្យរម្យមកលើកម្មការិនីផ្នែក ខែនឌី។ បន្ថែមពីលើនេះទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមហ៊ុនគួរតែមានវិធានការសមស្របណាមួយដើម្បីធានាថា លោក ចន្ទ័ អាន មិនបន្តប្រើពាក្យមិនសមរម្យនេះតទៅទៀត។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនបញ្ឈប់លោក ច័ន្ទ អាន ពីការងារ។

យោងតាមអង្គហេតុដែលបានរកឃើញ អង្គច្បាប់ និងហេតុផលដូចបានការពន្យល់ខាងដើម ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅនេះ:

THE ARBITRATION COUNCIL

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី២ :** បដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនបញ្ឈប់លោក ច័ន្ទ អាន ពីការងារ ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **អ៊ុច សុទ្ធី**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អន ណន**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **ប៉ែន ប៊ុនឈា**

ហត្ថលេខា: ------------------------------